**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ២០០០ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក/- មេដាយមាសការងារ**

១. លោក ទី សុគន្ធ ប្រធាននាយកដ្ឋាន រុក្ខា- ប្រមាញ់

**ខ/- មេដាយប្រាក់ការងារ**

| | | | |
|---|---|---|---|
| ១- | លោក | អ៊ុក ស៊ីផាន | អនុប្រធាននាយកដ្ឋានរុក្ខា- ប្រមាញ់ |
| ២- | លោក | ជា សំអាង | អនុប្រធាននាយកដ្ឋានរុក្ខា- ប្រមាញ់ |
| ៣- | លោក | វណ្ណ សុផាណ្ណា | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប |
| ៤- | លោក | ហ៊ួត ប៊ុនណារី | អនុប្រធាននាយកដ្ឋានរុក្ខា- ប្រមាញ់ |

| | |
|---|---|
| ៥- លោក អ៊ុង សំអាត | អនុប្រធាននាយកដ្ឋានរុក្ខា- ប្រមាញ់ |
| ៦- លោក កៅ ណាត | អតីតអភិបាលគង្គារុក្ខា- ប្រមាញ់ដើមខ្សែថ្នាក់ផុតលេខ |
| ៧- លោក ហ៊ាន ឈាង | អតីតអភិបាលគង្គារុក្ខា- ប្រមាញ់ដើមខ្សែថ្នាក់ផុតលេខ |
| ៨- លោក មាស សាន | អតីតប្រធានការិយាល័យកិច្ចការព្រៃឈើ |
| ៩- លោកស្រី សឹង ស៊ិនឌី | អតីតប្រធានការិយាល័យរដ្ឋបាល- ចាត់តាំង |
| ១០- លោក អៀង សាវើត | អនុប្រធានការិយាល័យកិច្ចការព្រៃឈើ |
| ១១- លោក ឆេង គីមស៊ុន | ប្រធានការិយាល័យកិច្ចការព្រៃឈើ |
| ១២- លោក ថោង ប៊ុនថន | អនុប្រធានការិយាល័យនីតិកម្ម-វិវាទ |
| ១៣- លោក ស៊ិន ហ៊ាន | អនុប្រធានការិយាល័យការពារសត្វព្រៃ |
| ១៤- លោក អ៊ីង អូ | ប្រធានការិយាល័យនីតិកម្ម-វិវាទ |
| ១៥- លោក ចាន់ ចេស្តា | ប្រធានការិយាល័យរុក្ខា- ប្រមាញ់ខេត្តមណ្ឌលគិរី |
| ១៦- លោក ម៉ា សុខថា | ប្រធានការិយាល័យដាំឈើ |
| ១៧- លោក ពូ ផានសៃ | អនុប្រធានការិយាល័យនីតិកម្ម-វិវាទ |
| ១៨- លោក សូ សារ៉ម | អនុប្រធានការិយាល័យរុក្ខា- ប្រមាញ់ខេត្តសៀមរាប |
| ១៩- លោក វង្ស សារុន | ប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ |
| ២០- លោក ហួត ពន្លឺ | ប្រធានការិយាល័យផែនការ- គណនេយ្យ |
| ២១- លោកស្រី ខៀវ ឆដា | មន្ត្រីការិយាល័យ រដ្ឋបាល- ចាត់តាំង |
| ២២- លោក ប៊ុច ធុច | មន្ត្រីការិយាល័យ រដ្ឋបាល- ចាត់តាំង |
| ២៣- លោក សូត្រ អុន | អនុប្រធានការិយាល័យដាំឈើ |
| ២៤- លោក វ័ត្ត ប៊ុនធឿន | មន្ត្រីការិយាល័យការពារសត្វព្រៃ |
| ២៥- លោក នុត អ៊ុនវ័ណហេង | ប្រធានសហគ្រាសចំរុះកូឡិចស៊ីម |
| ២៦- លោក លី ជូបៀង | អនុប្រធានការិយាល័យដាំឈើ |
| ២៧- លោក ទឹម ស៊ីផា | ប្រធានក្រុមហ៊ុនកាំហ្វ៊ិចស៊ីម |
| ២៨- លោក វ័ត្ត សុវណ្ណារ៉ា | មន្ត្រីការិយាល័យ នីតិកម្ម-វិវាទ |
| ២៩- លោក ថន សារ៉ាត | អនុប្រធានការិយាល័យផែនការ- គណនេយ្យ |
| ៣០- លោក ហ៊ឹម វិសាល | មន្ត្រីការិយាល័យដាំឈើ |
| ៣១- លោក នួន ធានា | ប្រធានសហគ្រាសដឹកជញ្ជូនផលព្រៃឈើ |
| ៣២- លោក ញឹក រតនៈពេជ្រ | អនុប្រធានការិយាល័យការពារសត្វព្រៃ |
| ៣៣- លោក អន ជា | អនុប្រធានការិយាល័យរដ្ឋបាល- ចាត់តាំង |
| ៣៤- លោក ឈុំ សុវណ្ណនី | មន្ត្រីការិយាល័យដាំឈើ |
| ៣៥- លោក ជីប ប៊ុនថាវិន | អនុប្រធានការិយាល័យរដ្ឋបាល- ចាត់តាំង |
| ៣៦- លោក យៀង អៀងគិច | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |

| | |
|---|---|
| ៣៧- លោកហង់ ស៊ុនត្រា | អនុប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ |
| ៣៨- លោក មាស មករា | មន្ត្រីការិយាល័យ កិច្ចការព្រៃឈើ |
| ៣៩- លោក លិ វុឌ្ឍី | អនុប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ |
| ៤០- លោក ឈៀង គុលា | មន្ត្រីការិយាល័យ នីតិកម្ម-វិវាទ |
| ៤១- លោក ចាន់ សុផល | អនុប្រធានវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ |
| ៤២- លោក ឯម មុនី | អនុប្រធានការិយាល័យរុក្ខា- ប្រមាញ់ខេត្តសៀមរាប |
| ៤៣- លោក ទេព សាម៉ៃ | មន្ត្រីការិយាល័យដាំឈើ |
| ៤៤- លោកស្រី ងួន ចរិយា | អនុប្រធានការិយាល័យផែនការ- គណនេយ្យ |
| ៤៥- លោក សួន ប៊ុនថន | អនុប្រធានការិយាល័យដាំឈើ |
| ៤៦- លោក រស់ សារ័ត្ន | មន្ត្រីការិយាល័យដាំឈើ |

**គ/- មេដាយសេវាការងារ**

| | |
|---|---|
| ១- លោក ទៀង សុខុម | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ២- លោក ឃូ សុខហេង | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ៣- លោក ប៉ក់ ជាលី | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ៤- លោក ព្រាប សំ | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ៥- លោក ប៊ុន រាដា | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ៦- លោកស្រី ស៊ន សុមុលីន | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ៧- កញ្ញា សៅ ចាន់ថុល | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ៨- លោក អោម សុផាណា | មន្ត្រីការិយាល័យកិច្ចការព្រៃឈើ |
| ៩- លោក គង់ ឈាន | មន្ត្រីការិយាល័យ នីតិកម្ម-វិវាទ |
| ១០- លោក ពិន ផានី | មន្ត្រីការិយាល័យ នីតិកម្ម-វិវាទ |
| ១១- លោក ចាប ចាន់ថុល | មន្ត្រីក្រុមហ៊ុនកាំហ្វ៊ិចស៊ីម |
| ១២- លោក ញ៉ាន ប៊ុនថន | មន្ត្រីការិយាល័យការពារសត្វព្រៃ |
| ១៣- លោក សេង គីមហ៊ត់ | មន្ត្រីការិយាល័យការពារសត្វព្រៃ |
| ១៤- លោក អ៊ុក គីមសាន | មន្ត្រីការិយាល័យការពារសត្វព្រៃ |
| ១៥- លោក ស៊ិន ប៉ូលីន | មន្ត្រីការិយាល័យការពារសត្វព្រៃ |
| ១៦- លោក ត្រី មះផល | មន្ត្រីការិយាល័យការពារសត្វព្រៃ |
| ១៧- លោក ម៉ែន ស៊ិយន៍ | មន្ត្រីការិយាល័យការពារសត្វព្រៃ |
| ១៨- លោក សួន ផល្លា | មន្ត្រីការិយាល័យការពារសត្វព្រៃ |

១៩- លោក គីមហ៊ាន ច័ន្ទសុភក្រ្តា មន្ត្រីវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ

២០- លោក ស សិទ្ធិ មន្ត្រីវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ

២១- លោក ទិត ណារ៉ា មន្ត្រីវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ

២២- លោក ហែម សារ៉ាវុធ មន្ត្រីវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ

២៣- លោក ហុង ចំណាន មន្ត្រីវិទ្យាស្ថានសិក្សាស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា២
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧ សសរ

# សេចក្ដីសំរេច

## ស្ដីពីការព្យួរការងារមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / កេម / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ / អនក្រ / បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ត្រូវបានព្យួរការងាររបស់លោក អ៊ុំ ទិចិត្រ បច្ចុប្បន្នប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងសុខាភិបាល ជាបណ្ដោះអាសន្ន ដើម្បីធ្វើអធិការកិច្ច ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ..០៧..ស.រ

## សារាចរ
## ស្តីពី
## ការត្រៀមកាត់បន្ថយ និងគ្រប់គ្រងគ្រោះមហន្តរាយ

គ្រោះមហន្តរាយដោយសារទឹកជំនន់ក្នុងឆ្នាំ២០០០ នៅព្រះរាជាណាចក្រកម្ពុជា បានជះឥទ្ធិពលយ៉ាងខ្លាំងដល់សក្តានុពល សេដ្ឋកិច្ច សង្គមកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ហើយគ្រោះទឹកជំនន់នេះ ក៏បានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ និងមានវិសាលភាពធំធេងជាងឆ្នាំណាៗទាំងអស់ នៃប្រវត្តិគ្រោះមហន្តរាយដោយសារទឹកជំនន់ក្នុងរយៈពេលជាង៧០ឆ្នាំកន្លងមក ។ មនុស្សចំនួន ៣៤៧នាក់ ក្នុងនេះមាន ៨០%ជាកុមារ ត្រូវស្លាប់ ប្រជាជនប្រមាណ ៣.៥លាននាក់ត្រូវបានទទួលរងគ្រោះ ក្នុងនេះមានប្រជាជនប្រមាណ ១០% ត្រូវបានជន្លៀសចេញជាបណ្តោះអាសន្នទៅកាន់ទីទួលមានសុវត្ថិភាព ។ ដំណាំស្រូវ និង ដំណាំរួមផ្សំ រាប់សែនហិកតា ត្រូវរងនូវការខូចខាតទាំងស្រុង ។ សាលារៀន វត្តអារាម មន្ទីរពេទ្យ និង ផ្ទះសម្បែងប្រជាពលរដ្ឋជាច្រើនកន្លែងត្រូវរងការខូចខាត ។ ដោយឡែក ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិដូចជា ផ្លូវជាតិ ស្ពាន ផ្លូវលំជនបទត្រូវកាត់ផ្តាច់ ហើយប្រព័ន្ធធារាសាស្ត្រជាច្រើនកន្លែងត្រូវរងការខូចខាត ។ តាមការប៉ាន់ស្មានអំពីការបំផ្លិចបំផ្លាញដោយផ្ទាល់ពីគ្រោះមហន្តរាយដោយសារទឹកជំនន់ឆ្នាំ ២០០០ នេះ ទំហំនៃការខូចខាតមានតំលៃសរុបប្រមាណ ១៥០លានដុល្លារអាមេរិក ។

ក្នុងរយៈពេលប៉ុន្មានខែដើមឆ្នាំ ២០០១នេះ អាកាសធាតុមានការប្រែប្រួល បំលាស់ប្តូរកើតមានបាតុភូតបរិយាកាស អែល នីណូ (El nino ) ក្តៅ និងឡា នីណា (La nina) ត្រជាក់ ហើយប្រទេសមួយចំនួនក្នុងទ្វីបអាស៊ីក៏បាននិងកំពុងជួបប្រទះនឹងគ្រោះទឹកជំនន់លិចលង់ផងដែរ ។

ជាក់ស្តែងនៅចុងខែ មិថុនា ឆ្នាំ ២០០១កន្លងមកថ្មីៗនេះ នៅក្នុងស្រុក០២ របស់ខេត្តកោះកុងនៃព្រះរាជាណាចក្រកម្ពុជា បានទទួលរងគ្រោះដោយទឹកជំនន់ បណ្តាលមកពីទឹកភ្លៀងធ្លាក់ជោគជាំ ធ្វើឱ្យផលដំណាំកសិកម្មរបស់បងប្អូនប្រជាកសិករជាច្រើនហិកតាត្រូវខូចខាត សត្វពាហនៈសត្វស្លាប ជាច្រើនក្បាលត្រូវស្លាប់ និងផ្លូវលំ០១ខ្សែត្រូវកាត់ផ្តាច់ជាច្រើនកន្លែង ។

ចំណែកនៅបណ្តាប្រទេសមួយចំនួនផ្សេងទៀតលើពិភពលោក ថ្វីត្បិតតែមានខឿនសេដ្ឋកិច្ច

រីកលូតលាស់ក៏ដោយ ក៏នៅតែទទួលរងនូវគ្រោះមហន្តរាយ ដូចជាការធ្លាក់យន្តហោះ គ្រោះថ្នាក់នាវាជលយានកើតមាននៅតាមផ្លូវទឹក គ្រោះថ្នាក់យានយន្តតាមផ្លូវគោក គ្រោះថ្នាក់រថភ្លើងតាមផ្លូវដែក និងគ្រោះថ្នាក់ក្នុងផ្នែកឧស្សាហកម្ម ព្រមទាំងបាតុភូតធម្មជាតិផ្សេងៗ ដូចជាការរញ្ជួយដី បន្ទុះភ្នំភ្លើង និងទឹកជំនន់ផងដែរ ។

យោងទៅលើបទពិសោធន៍ និងស្ថានភាពគ្រោះមហន្តរាយដោយទឹកជំនន់ ដែលបានកើតឡើងក្នុងឆ្នាំ ២០០០ កន្លងមក រាជរដ្ឋាភិបាល សូមដាក់ចេញនូវគោលការណ៍សំរាប់អនុវត្តមួយចំនួន ដើម្បីត្រៀមកាត់បន្ថយ និងគ្រប់គ្រងគ្រោះមហន្តរាយនៅព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

១- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវពង្រីកខ្សែរយៈរបស់ខ្លួនឱ្យដល់មូលដ្ឋានខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ដើម្បីងាយស្រួលក្នុងការប្រមូលទិន្នន័យ សំរបសំរួលទំនាក់ទំនងសំរាប់ធ្វើជាមូលដ្ឋានច្បាស់លាស់ ក្នុងការរាយការណ៍ជូនរាជរដ្ឋាភិបាលមានវិធានការ និងដោះស្រាយបានទាន់ពេលវេលា ។

-ក្រសួង ស្ថាប័នមានការពាក់ព័ន្ធត្រូវចាត់តាំងមន្ត្រីចំនួន ០៣នាក់ សំរាប់ធ្វើការសំរបសំរួល ក្នុងនោះមានមន្ត្រីម្នាក់ប្រចាំការនៅ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

-នៅថ្នាក់ខេត្ត-ក្រុង ត្រូវចាត់តាំងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង និងលេខាធិការដ្ឋានអចិន្ត្រៃយ៍ខេត្ត-ក្រុងជាជំនួយការ ដោយមានមន្ត្រីជំនាញមានបទពិសោធន៍សំរាប់ជួយការងារ ។

-នៅថ្នាក់ស្រុក-ខ័ណ្ឌត្រូវចាត់តាំងដូចនៅថ្នាក់ខេត្ត-ក្រុងដែរ ប៉ុន្តែមានមន្ត្រី០២នាក់ជាជំនួយការសំរាប់បំរើការងារគ្រោះមហន្តរាយ ។

២-ត្រូវផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេល ២ឆ្នាំ (២០០១-២០០២ )ដែលបានធ្វើការវាយតំលៃ និងធ្វើសិក្ខាសាលារួចហើយ ដោយមានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាល ដូចមានចែងក្នុងលិខិតលេខ ៦៣៦ សជណ.សរចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រីកន្លងមក ព្រមទាំងធ្វើការផ្សព្វផ្សាយអំពីបទពិសោធន៍ល្អៗ ដែលទទួលបានក្នុងពេលមានគ្រោះទឹកជំនន់ឆ្នាំ២០០០ ។

៣-ត្រូវធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀត ចំពោះការចូលរួមពីមន្ទីរជំនាញនានា ដែលជា

សមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ដោយធ្វើការប្រជុំវិភាគប៉ាន់ប្រមាណអំពីមុខសញ្ញាគ្រោះថ្នាក់ និងភាពងាយរងគ្រោះថ្នាក់ ដើម្បីរៀបចំផែនការអន្តរាគមន៍ សង្គ្រោះបន្ទាន់ និងកំណត់ការទទួលខុសត្រូវរបស់មន្ទីរជំនាញតាមភារកិច្ចរៀងៗខ្លួន ។

៤-ត្រូវរៀបចំផែនទីទឹកជំនន់ ដោយកំណត់តំបន់ងាយរងគ្រោះ ទីទួលសុវត្ថិភាព (វត្តអារាម សាលារៀន ...) សំរាប់ធ្វើការជន្លៀសប្រជាជនរងគ្រោះ រៀបចំផ្លាកសញ្ញាសំគាល់កន្លែងគ្រោះថ្នាក់ និងរៀបចំកែលំអទំនប់ការពារទឹកជំនន់ ព្រមទាំងចាត់តាំងឱ្យមានការតាមដានត្រួតពិនិត្យជាប្រចាំនៅតាមកន្លែងដែលធ្លាប់រងគ្រោះដោយទឹកហូរចូល ។

៥-កំណត់អំពីចំនួនមធ្យោបាយ ទូក កាណូត ដែលមានក្នុងខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ជារបស់រដ្ឋក្តី ឯកជនក្តី នៅពេលមានទឹកជំនន់កើតឡើង គឺត្រូវចលនាឱ្យគេចូលរួមជួយដឹកជញ្ជូន ជន្លៀសប្រជាជនចេញពីតំបន់រងគ្រោះ និងងាយរងគ្រោះ ដោយចាំបាច់ត្រូវធ្វើកិច្ចសហការជាមួយកងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដើម្បីរៀបចំកំលាំងអន្តរាគមន៍ជួយសង្គ្រោះ ឱ្យបានទាន់ពេលវេលា ។

៦-ត្រូវធ្វើការអប់រំឱ្យបានជាប្រចាំ ដើម្បីបង្កើនការយល់ដឹងដល់មហាជន អំពីផលប៉ះពាល់នៃគ្រោះថ្នាក់ ស្មារតីប្រុងប្រយ័ត្នក្នុងការត្រៀមរៀបចំកំលាំងក្នុងសហគមន៍ សំរាប់ជួយសង្គ្រោះអាយុជីវិត និងកាត់បន្ថយការខូចខាតទ្រព្យសម្បត្តិពេលមានគ្រោះទឹកជំនន់កើតឡើង ។

៧-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមក្នុងសេចក្តីព្រាងច្បាប់សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ នូវថវិកាមួយដាច់ដោយឡែក សំរាប់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងចង្កោមថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដូចជាថវិការបស់រដ្ឋលេខាធិការដ្ឋានដទៃទៀតដែរ ។ ក្នុងរយៈពេលខ្លីទៅមធ្យម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តត្រៀមថវិកានៅក្នុងជំពូកចំណាយពុំបានគ្រោងទុក សំរាប់ដោះស្រាយតំរូវការបន្ទាន់ទាំងឡាយដែលអាចកើតមានជាយថាហេតុដោយសារគ្រោះធម្មជាតិនានា ។

៨-ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ត្រូវរៀបចំឡើងនូវ "អង្គភាពអន្តរាគមន៍សង្គ្រោះបន្ទាន់ "ដើម្បីហ្វឹកហ្វឺនដល់កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ

និងក្រុមគ្រូពេទ្យនូវបច្ចេកទេសចាំបាច់សំរាប់ការងារសង្គ្រោះបន្ទាន់ ក្នុងពេលមានគ្រោះមហន្តរាយកើតឡើងជាយថាហេតុ ។

៩-ក្រសួងធនធានទឹក និងឧតុនិយម ត្រូវខិតខំយកចិត្តទុកដាក់ថែមទៀត លើការបង្កើនគុណភាពព្យាករណ៍អាកាសធាតុ និងទឹកជំនន់ ដោយអនុវត្តការព្យាករណ៍ប្រចាំសប្តាហ៍ ដើម្បីឱ្យប្រជាពលរដ្ឋអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមលក្ខណៈជាមុន ក្នុងគោលបំណងកាត់បន្ថយបាននូវគ្រោះមហន្តរាយ ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយត្រូវសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយពត៌មានព្យាករណ៍នៅក្នុងតំបន់ដែលនឹងត្រូវទទួលរងគ្រោះ ។

១០-គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវយកចិត្តទុកដាក់ដល់កិច្ចសហប្រតិបត្តិការ និងការសំរបសំរួលការងារជាមួយក្រសួង ស្ថាប័ន កាកបាទក្រហមកម្ពុជា ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលទាំងអស់ ដើម្បីការពារ និងបង្ការគ្រោះមហន្តរាយផ្សេងៗនៅកម្ពុជា ។

១១-នៅពេលមានហេតុការណ៍កើតឡើង អាជ្ញាធរមូលដ្ឋានសាមីត្រូវផ្តល់ពត៌មាន តាមលំដាប់ថ្នាក់ឱ្យបានទាន់ពេលវេលា និងធ្វើការវាយតំលៃឱ្យបានច្បាស់លាស់ ដោយពិភាក្សាជាមួយមន្ទីរពាក់ព័ន្ធតាមខេត្ត-ក្រុង ហើយករណីចាំបាច់ ត្រូវពិគ្រោះយោបល់ជាមួយអង្គការអន្តរជាតិនានាដែលប្រចាំការនៅមូលដ្ឋានរបស់ខ្លួននោះ ដើម្បីរកវិធានការដោះស្រាយជាបន្ទាន់ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន និងអាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង ជាពិសេសគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ត្រូវយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយ និងចាត់ចែងអនុវត្តឱ្យសំរេចបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ :..០៣..សរ.ណ

# សារាចរ

## ស្តីពីការដាក់មន្ត្រីរាជការស៊ីវិល

## ឲាំងពីរភេទអោយចូលនិវត្តន៍

ផ្អែកតាមខ្លឹមសារនៃព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រឹត្យលេខ ជស រកត ១២៩៧/២៧៣ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ក្រសួង ស្ថាប័នមួយចំនួនត្រូវកសាងលក្ខន្តិកៈដោយឡែកសំរាប់ក្របខ័ណ្ឌនីមួយៗ ។ រាជរដ្ឋាភិបាលបានប្រកាសផ្សាយរួចហើយ នូវព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមួយចំនួន ឯលក្ខន្តិកៈដោយឡែកមួយចំនួនទៀត កំពុងតែកសាងឡើងជាបន្តបន្ទាប់ ។ ក្នុងស្ថានភាពដែលយើងពុំទាន់បានធ្វើសមាហរណកម្មក្របខ័ណ្ឌបច្ចុប្បន្នផ្ទេរចូលទៅក្នុងក្របខ័ណ្ឌថ្មី នៃលក្ខន្តិកៈដោយឡែកនោះ ក្រសួង ស្ថាប័ននីមួយៗ ជួបការលំបាកក្នុងការរៀបចំដាក់មន្ត្រីរាជការស៊ីវិលអោយចូលនិវត្តន៍ ។ ដូចនេះ ដើម្បីអោយស្របនឹងស្ថានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការកំណត់លក្ខខ័ណ្ឌនៃការចូលនិវត្តន៍របស់មន្ត្រីរាជការស៊ីវិលដូចតទៅ ÷

**១_មន្ត្រីដែលដល់អាយុ ៦០ ឆ្នាំ ត្រូវចូលនិវត្តន៍ :**

ក-មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មាន :

-អគ្គនាយក-អគ្គលេខាធិការ-អគ្គាធិការ-អភិបាលខេត្តក្រុង

-អគ្គនាយករង-អគ្គលេខាធិការរង-អគ្គាធិការរង-អធិការ-ប្រធាននាយកដ្ឋាន-អភិបាលរងខេត្តក្រុង

-អនុប្រធាននាយកដ្ឋាន- អធិការរង-ប្រធានមន្ទីរខេត្តក្រុង-អភិបាលស្រុកខ័ណ្ឌ

-និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ។

ខ-មន្ត្រីកំពុងបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្នចាប់ពី ក II –៧ ឡើងទៅ ។

គ-មន្ត្រីដែលមានប្រភេទកាំបៀវត្សបច្ចុប្បន្ន ខ I ឬ មន្ត្រីដែលមានសញ្ញាប័ត្រសមមូលនឹងបរិញ្ញាប័ត្រឡើងទៅ ។

ឃ-មន្ត្រីដែលបំរើការងារក្នុងក្របខ័ណ្ឌគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងអស់ និងគ្រូបង្រៀនអចិន្ត្រៃយ៍នៅតាមសាកលវិទ្យាល័យ មហាវិទ្យាល័យ និងសាលាមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងនានា ហើយដែលបានទទួលប្រាក់កំរៃគរុកោសល្យ ។

២-មន្ត្រីដែលដល់អាយុ ៥៨ ឆ្នាំ ត្រូវចូលនិវត្តន៍ :

ក-មន្ត្រីដែលកំពុងកាន់មុខតំណែងពិតប្រាកដក្នុងអង្គការលេខនៃរចនាសម្ព័ន្ធ នៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន មាន :

-ប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល-អភិបាលរងស្រុកខ័ណ្ឌ-អនុប្រធានមន្ទីរនៅខេត្តក្រុង

-អនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាល-ប្រធានការិយាល័យនៃមន្ទីរខេត្តក្រុង

-អនុប្រធានការិយាល័យនៃមន្ទីរខេត្តក្រុង

-និងមុខតំណែងឯទៀត ដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ស្ថាប័ន ។

ខ-មន្ត្រីកំពុងបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ ដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្នចាប់ពី ក II –១០ ដល់ ក II -៨ ។

គ-មន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ខ II ឬ មន្ត្រីដែលមានសញ្ញាប័ត្រសមមូលនឹងសញ្ញាប័ត្រមធ្យមសិក្សាឯកទេស ។

៣-មន្ត្រីដែលដល់អាយុ ៥៥ ឆ្នាំ ត្រូវចូលនិវត្តន៍គឺ : មន្ត្រីដែលមានប្រភេទកាំប្រៀវត្សបច្ចុប្បន្ន ក II-១១ ខ III - ខ IV- គ I – គ II – គ III និង គ IV ។

៤-ករណីមន្ត្រីដែលមានអាយុ ៥៥ ឆ្នាំឡើង ហើយកំពុងកាន់មុខតំណែង ឬមានល័ក្ខខ័ណ្ឌដូច ចំណុច ១ និង ២ខាងលើ តែមិនទាន់បានដាក់អោយចូលនិវត្តន៍ ត្រូវនៅបន្តការងាររហូតដល់អាយុកំណត់ចូលនិវត្តន៍គឺ ៦០ ឆ្នាំ ឬ ៥៨ ឆ្នាំ ។

បើមានការលំបាកស្មុគស្មាញក្នុងការអនុវត្តន៍ គ្រប់ក្រសួង ស្ថាប័ន ត្រូវពិគ្រោះយោបល់ជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីពិនិត្យដោះស្រាយ ។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់ខេត្ត ក្រុង

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

№ ៤៣០ ឧរ៥ ឧតស-ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

## ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ១៧៣ ឧរថឧតស.ប្រក ចុះថ្ងៃទី ០៧-៣-០១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតពោះវៀនកង់-ម៉ូតូ "សំពៅ" របស់លោក លី ហុង ចុះថ្ងៃទី ០៥-៦-០១ ។

## សម្រេច

**ប្រការ១:-** អនុញ្ញាតអោយលោក **លី ហុង** ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៦៤៣៧ភ.ព ចុះថ្ងៃទី០១-៧-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៩C ផ្លូវលេខ២៨០ ក្រុមទី២៤ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតពោះវៀនកង់-ម៉ូតូ "សំពៅ" នៅក្នុងទីតាំង ផ្លូវទួលសង្កែ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**ប្រការ២:-** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៣:-** ប្រកាសលេខ ១៧៣ ឧរថឧតស.ប្រក ចុះថ្ងៃទី ០៧-៣-០១ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:-** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង លោក **លី ហុង** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ៥:-** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុង ភ្នំពេញ
-ខណ្ឌ ឫស្សីកែវ
"ដើម្បីជ្រាប"
-ដូចប្រការ ៣ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ស៊ុយ សែម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ ៤៣១ ឧរថ.កស.ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី.....០៦.....ខែ..កក្កដា...ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បើកដំណើរការឧស្សាហកម្មតូចកែឆ្នៃដំឡូងមី "ប៊ូផា" របស់លោក ប៊ុល គុមហ៊ន ចុះថ្ងៃទី ០៦-៣-០១ ។
- បានការយល់ព្រមលេខ ៨២០ កច ចុះថ្ងៃទី ២០-៤-០១ របស់អភិបាល ខេត្តកំពង់ចាម ។

## សម្រេច

**ប្រការ១:-** អនុញ្ញាតអោយលោក **ប៊ុល គុមហ៊ន** ជនជាតិខ្មែរ កាន់លិខិតបញ្ជាក់លេខ ០៣/២០០១កច ចុះថ្ងៃទី២៥-៦-០១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិគោកស្រុក ឃុំគោកស្រុក ស្រុកតំបែរ ខេត្តកំពង់ចាម បើកដំណើរការឧស្សាហកម្មតូចកែឆ្នៃដំឡូងមី "ប៊ូផា" នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ២:-** លោក **ប៊ុល គុមហ៊ន** ត្រូវមកចុះបញ្ជីផលិតផល និង យកគំរូផលិតផលម្សៅដំឡូងមីរបស់ខ្លួនមកពិនិត្យគុណភាព នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មុននឹងចរាចរនៅលើទីផ្សារ ។

**ប្រការ៣:-** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួន ឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

**ប្រការ៤:-** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ចាម និង លោក **ប៊ុល គុមហ៊ន** ត្រូវទទួលអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ៥:-** ប្រកាសនេះមានអនុភាពចតិកុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្ត កំពង់ចាម
- សាលាស្រុក តំបែរ
  "ដើម្បីជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"

ស៊ុយ សែម

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

ភ្នំពេញ, ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ 2001

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៤៣៦ ឧរថអក.ប្រក

**ប្រកាសអន្តរក្រសួង**
**ស្តីពីការបញ្ចុះថ្លៃប្រើប្រាស់ថាមពលអគ្គិសនី**
**ចែកចាយដោយ អគ្គិសនីបាត់ដំបង**
**ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា**

**ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និង**
**រដ្ឋមន្ត្រី ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ លេខ នស/ រកត/ 1198/ 72 ចុះថ្ងៃទី 30 ខែ វិច្ឆិកា ឆ្នាំ 1998 ស្តីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី
- បានឃើញព្រះរាជក្រឹត្យលេខ ជ.ស/ រកត/ 0396-10 របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ចុះថ្ងៃទី 9 ខែ មីនា ឆ្នាំ 1996 ស្តីពីការបង្កើតអគ្គិសនីកម្ពុជា
- បានឃើញប្រកាសលេខ 552 បលប្រក ចុះថ្ងៃទី 28 ខែ មិថុនា ឆ្នាំ 2000 របស់ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការផ្ទេរអង្គភាព អគ្គិសនីបាត់ដំបង ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គិសនីកម្ពុជា
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ 105 សជណខស ចុះថ្ងៃទី 21 មករា 2000 ស្តីពីករណីសំណើសុំសំរេចជាបណ្តោះអាសន្នថ្លៃអគ្គិសនីនៅខេត្តបាត់ដំបង ។
- បានឃើញការចាំបាច់ចំពោះមុខ

<u>សំរេច</u>

<u>**ប្រការ 1**</u> - បញ្ចុះថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ចែកចាយដោយអង្គភាព អគ្គិសនីបាត់ដំបង ពី 0.27 ដុល្លារអាមេរិក ក្នុងមួយគីឡូវ៉ាត់ម៉ោងមកត្រឹម 0.245 ដុល្លារអាមេរិកវិញ ដោយទូទាត់ជាប្រាក់ដុល្លារឬជាប្រាក់រៀលទៅតាមអត្រាប្តូរប្រាក់ដុល្លារ-រៀលដូចធ្លាប់អនុវត្តកន្លងមក ។

<u>**ប្រការ 2**</u> - អគ្គិសនីកម្ពុជា និង អគ្គិសនីបាត់ដំបង មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

<u>**ប្រការ 3**</u> - ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តលើការប្រើប្រាស់ថាមពលអគ្គិសនីចាប់ពីខែ កក្កដា ឆ្នាំ 2001 តទៅ ។

**រដ្ឋមន្ត្រីក្រសួង**
**ឧស្សាហកម្ម រ៉ែ និង ថាមពល**

សុីុយ_តែងម

**ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រី**
**ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

<u>**ចម្លងជូន :**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង មហាផ្ទៃ
- ឯ.ឧ អភិបាលខេត្តបាត់ដំបង
- ប្រធាន ក្រុមប្រឹក្សាភិបាល អគ្គិសនីកម្ពុជា
- ដូចក្នុងប្រការ 2
- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខៈ ៥៦៣ ប.ស្ត

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ៧ ឆ្នាំ ២០០១

# ប្រ ក ា ស

## រដ្ឋមន្ត្រី ក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងបរិស្ថាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ។
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង ។
- យោងលិខិតចុះបញ្ជីពាណិជ្ជកម្មលេខ ១៩៧៨ ពណ.នតក ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០០១ ។
- យោងលិខិតសាលាក្រុងភ្នំពេញលេខ ១២៩៤ ឆត.ស ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០០១ ។
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន **សារ៉ុំ ត្រេឌីង** ខូអេលធីឌី ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០០១ ។

# សំរេច

**ប្រការ ១** : អនុញ្ញាតឱ្យក្រុមហ៊ុន សា រ៉ុំ ត្រេឌីង កូអេលធីឌី ( Sa Rom Trading Co., Ltd ) តំណាងដោយលោក យូ សារ៉ុំ ភេទប្រុស អាយុ ២៩ ឆ្នាំ ជនជាតិខ្មែរ ជានាយកក្រុមហ៊ុន មានអាស័យដ្ឋានផ្ទះលេខ $122AE_0$ ផ្លូវ 430 សង្កាត់ទួលទំពូង ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បង្កើតទីតាំងចាក់សំណល់ឧស្សាហកម្ម និងដំណើរការអាជីវកម្មប្រមូល-ដឹកជញ្ជូន និងទុកដាក់សំណល់រោងចក្រឧស្សាហកម្មផ្តាច់មុខ ក្នុងទីក្រុងភ្នំពេញនិងខេត្តកណ្តាល ។

**ប្រការ ២** : ក្នុងការបង្កើតទីតាំងចាក់សំណល់នេះ ក្រុមហ៊ុនត្រូវធ្វើប្លង់ ធ្វើគំរោងសិក្សាលទ្ធភាពបង្កើតទីតាំង និងធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយមានការបញ្ជាក់ពីវិធានការណ៍ការពារហេតុប៉ះពាល់បរិស្ថានច្បាស់លាស់ និងដោយមានការឯកភាពពីស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីជាមុន ។

**ប្រការ ៣** : ក្នុងកិច្ចដំណើរការសាងសង់ទីតាំងចាក់សំណល់នេះ ក្រុមហ៊ុនត្រូវអនុវត្តន៍តាមគោលការណ៍ណែនាំ ដែលបានកំណត់ដោយស្ថាប័នជំនាញ ។

**ប្រការ ៤** : ក្នុងកិច្ចដំណើរការអាជីវកម្មប្រមូល-ដឹកជញ្ជូននិងទុកដាក់សំណល់រោងចក្រឧស្សាហកម្ម ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពសាធារណៈ និងធានាការការពារគុណភាពបរិស្ថានជុំវិញទីតាំងចាក់សំណល់ និងត្រូវធ្វើរបាយការណ៍ប្រចាំខែជូនមកក្រសួងបរិស្ថាន អំពីបរិមាណសំណល់ដែលបានប្រមូល និងពីការទុកដាក់សំណល់ ។

**ប្រការ ៥** : ប្រកាសអនុញ្ញាតឱ្យបង្កើតនិងដំណើរការអាជីវកម្មទីតាំងចាក់សំណល់នេះ មានតំលៃរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើប្រកាសនេះតទៅ ។

**ប្រការ ៦** : ក្រោយទទួលបានប្រកាសអនុញ្ញាតនេះ ក្រុមហ៊ុនត្រូវចាប់ផ្តើមដំណើរការសាងសង់ និងដំណើរការអាជីវកម្មទីតាំងចាក់សំណល់ជាបន្ទាន់ ។ ក្នុងករណី ដែលក្រុមហ៊ុនមិនបានអនុវត្តន៍ការសាងសង់ទីតាំងចាក់សំណល់ ក្រោយទទួលបានប្រកាសអនុញ្ញាតរយៈពេល ១ ឆ្នាំ ប្រកាសអនុញ្ញាតនេះនឹងត្រូវដកហូតមកវិញជាស្ថាពរ ។

**ប្រការ ៨** : ក្នុងករណីដែលក្រុមហ៊ុនប្រព្រឹត្តល្មើសនឹងច្បាប់ រឺល្មើសធ្ងន់ធ្ងរទៅនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសអនុញ្ញាតនេះនឹងត្រូវដកហូតមកវិញជាស្ថាពរ ។

**ប្រការ ៨** : អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ប្រធាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាននៃក្រសួងបរិស្ថាន ប្រធានមន្ទីរបរិស្ថានរាជធានីភ្នំពេញ ប្រធានមន្ទីរបរិស្ថានខេត្តកណ្តាល និង នាយកក្រុមហ៊ុន សា រ៉ុ គ្រេឌីង កូអេលធីឌី ត្រូវអនុវត្តន៍ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ ៩** : ប្រកាសនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

បណ្ឌិត.ជីវ៉ាទុរ្យា

ចំលងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- សាលាក្រុងភ្នំពេញ
- សាលាខេត្តកណ្តាល

" ដើម្បីជូនជ្រាប "
- មន្ទីរបរិស្ថានរាជធានីភ្នំពេញ
- មន្ទីរបរិស្ថានខេត្តកណ្តាល

" ដើម្បីសហការអនុវត្តន៍ "
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**

**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ......១៤៩៥......សកបយ

ភ្នំពេញ,ថ្ងៃទី០៧...ខែកក្កដា ឆ្នាំ ២០០១

## ប្រកាស

## ស្តីពី

## សៀវភៅការងារកម្មករនិយោជិតខ្មែរ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស.រកម-០៣៩៧-០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

# ស ំ រេ ច

ប្រការ ១: ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ មិនអាចប្រើកម្មករនិយោជិតខ្មែរដោយគ្មានសៀវភៅការងារឡើយ ហើយត្រូវបង្កលក្ខណៈងាយស្រួលឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទៅធ្វើសៀវភៅការងារ នៅឯនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះអ្នកនៅរាជធានីភ្នំពេញ និងនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗ ចំពោះអ្នកនៅខេត្តក្រុង។

ប្រការ ២ : នៅពេលស្នើសុំសៀវភៅការងារកម្មករនិយោជិតម្នាក់ៗត្រូវយកទៅជាមួយនូវ :

- ពាក្យស្នើសុំសៀវភៅការងារបិទតែមប្រើយ ១ ០០០ រៀល ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខ ទំហំ ៣ គុណ ៤សម ចំនួន ៥សន្លឹក ចំនួន ០១ ច្បាប់
- អត្តសញ្ញាណប័ណ្ណជនជាតិខ្មែរ ឬ លិខិតបញ្ជាក់សញ្ជាតិខ្មែរដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច ឬលិខិតធានាខ្លួនថាជាជនជាតិខ្មែរដោយមានការបញ្ជាក់របស់កម្មករដែលធ្វើការជាមួយគ្នាចំនួន២នាក់ដែលមានអត្តសញ្ញាណជាខ្មែរ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់មុខរបរដែលចេញឱ្យដោយម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន ចំនួន ០១ ច្បាប់
- អាករសៀវភៅការងារដែលកំណត់ឱ្យបង់តែម្តងគត់ចំនួន១ ៥០០រៀល( មួយពាន់ប្រាំរយរៀលគត់) ។

ប្រការ ៣ : ពេលជាមួយគ្នានឹងការចេញសៀវភៅការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ឬ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗ ក៏មានចេញជូនសាមីជនកម្មករនិយោជិតផងដែរនូវ " ប័ណ្ណសំគាល់កម្មករនិយោជិតខ្មែរ " ។

ប្រការ ៤ : នៅពេលដែលមានកម្មករនិយោជិតចូលធ្វើការ ឬឈប់ពីការងារ សហគ្រាសគ្រឹះស្ថានណាមួយ ម្ចាស់ ឬ នាយកសហគ្រាសគ្រឹះស្ថាន ត្រូវយកសៀវភៅការងាររបស់កម្មករនិយោជិតនោះ ទៅចុះទិដ្ឋាការចូល ឬ ចេញ នៅឯនាយកដ្ឋានមុខរបរនិងហត្ថពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះអ្នកនៅរាជធានីភ្នំពេញ ឬនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗ ចំពោះអ្នកនៅខេត្តក្រុង។ ការចុះទិដ្ឋាការនេះត្រូវធ្វើក្នុងរយៈពេលមិនលើសពី ៧ថ្ងៃ គិតចាប់ពីថ្ងៃដែលសាមីកម្មករនិយោជិតបានចូលធ្វើការ ឬ ឈប់ពីការងារ។

នៅពេលដែលមានការផ្លាស់ប្តូរមុខងារ និងប្រាក់ឈ្នួល របស់កម្មករនិយោជិតម្តងៗ ម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន ក៏ត្រូវយកសៀវភៅការងារទៅចុះទិដ្ឋាការឱ្យបានត្រឹមត្រូវដូចពេលចូលធ្វើការ ឬឈប់ពីការ

ងារផងដែរ ។

នៅពេលដែលកម្មករនិយោជិតឈប់ពីការងារ ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាស ត្រូវប្រគល់សៀវភៅការងារជូនដល់សាមីជនកម្មករនិយោជិតវិញ ។

ប្រការ៥ : ម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន មិនត្រូវបានអនុញ្ញាតិឱ្យយកសៀវភៅការងារកម្មករនិយោជិតទៅប្រើប្រាស់ខុសពីគោលដៅឡើយ ហើយក៏មិនអាចចារមូលវិចារអ្វីនៅលើសៀវភៅការងារនោះផងដែរ ។

ប្រការ ៦: អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញតិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូក១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ ៧ : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

-ខុទ្ទកាល័យព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ

-សហភាពសហជីព

" ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "

-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុង

-សមាគមនិយោជក

" ដើម្បីអនុវត្ត "

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍

" ដើម្បីជួយផ្សព្វផ្សាយ "

-កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*********

**ក្រសួងអប់រំយុវជន និងកីឡា**

លេខ : ៥០៤ អយក.ប្រក

# ប្រកាស

## ស្តីពីការកំណត់មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

### រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/_កម ០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជន និងកីឡា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១៨៥២ សជណ.អរ ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការលុបការប្រលងសញ្ញាប័ត្រមធ្យមសិក្សាលើកទី២ ។
- បានឃើញប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាលេខ ១២៦ អយក.ប្រក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។
- យោងសំណើរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្ត_ក្រុង ស្តីពីការសុំបើកមណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ តាមខេត្ត_ក្រុង ។

## សំ រេ ច

*ប្រការ១:* មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចំនេះទូទៅ និងបំពេញវិជ្ជា សម័យប្រឡងថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ត្រូវកំនត់ដូចតទៅ ÷

### I. រាជធានីភ្នំពេញ មាន០៩មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល អនុវិ. ចតុមុខ | ៤២បន្ទប់ | ខ័ណ្ឌដូនពេញ |
| ២. មណ្ឌល វិ. ច្បារអំពៅ | ៤២បន្ទប់ | ខ័ណ្ឌមានជ័យ |
| ៣. មណ្ឌល វិ. បឹងត្របែក | ៤២បន្ទប់ | ខ័ណ្ឌចំការមន |
| ៤. មណ្ឌល វិ. ទួលទំពូង | ៤២បន្ទប់ | ខ័ណ្ឌចំការមន |
| ៥. មណ្ឌល វិ. សន្ធរម៉ុក | ៤២បន្ទប់ | ខ័ណ្ឌទួលគោក |
| ៦. មណ្ឌល វិ. ឥន្ទ្រទេវី | ៤២បន្ទប់ | ខ័ណ្ឌទួលគោក |
| ៧. មណ្ឌល វិ. បាក់ទូក | ៤២បន្ទប់ | ខ័ណ្ឌ ៧មករា |
| ៨. មណ្ឌល វិ. វត្តកោះ | ៤២បន្ទប់ | ខ័ណ្ឌដូនពេញ |
| ៩. មណ្ឌល វិ. ព្រះស៊ីសុវត្ថិ | ៣៥បន្ទប់ ក្នុងនោះបំ.វិ.០២បន្ទប់ | ខ័ណ្ឌដូនពេញ |

### II. ខេត្តកណ្ដាល មាន០៧មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ. ហ. សតាខ្មៅ | ២៤បន្ទប់ | ស្រុកតាខ្មៅ |
| ២. មណ្ឌល អនុវិ. សេរីភាព | ២៣បន្ទប់ | ស្រុកតាខ្មៅ |
| ៣. មណ្ឌល វិ. កំពង់កន្ទួត | ២០បន្ទប់ ក្នុងនោះបំ.វិ.០៨បន្ទប់ | ស្រុកកណ្ដាលស្ទឹង |
| ៤. មណ្ឌល វិ. ទេព្យប្រណម្យ | ១៨បន្ទប់ | ស្រុកពញាឮ |
| ៥. មណ្ឌល វិ. សិរីមង្គល | ២១បន្ទប់ | ស្រុកមុខកំពូល |
| ៦. មណ្ឌល អនុវិ. ព្រែកឯង | ១៦បន្ទប់ | ស្រុកកៀនស្វាយ |
| ៧. មណ្ឌល វិ. ជ័យវរ្ម័នទី៧ | ២០បន្ទប់ | ស្រុកកៀនស្វាយ |

### III. ខេត្តកំពង់ចាម មាន០៤មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ. ព្រះសីហនុ | ៤៥បន្ទប់ ក្នុងនោះបំ.វិ.០៤បន្ទប់ | ស្រុកកំពង់ចាម |
| ២. មណ្ឌល វិ. ន. រ. គន្ធបុប្ផា | ១៨បន្ទប់ | ស្រុកព្រៃឈរ |
| ៣. មណ្ឌល វិ. ជីហែ | ១៤បន្ទប់ | ស្រុកកោះសូទិន |
| ៤. មណ្ឌល វិ. ត្បូងឃ្មុំ | ១៨បន្ទប់ | ស្រុកត្បូងឃ្មុំ |

### IV. ខេត្តតាកែវ មាន០៤មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ. ជា ស៊ីមតាកែវ | ២១បន្ទប់ | ស្រុកដូនកែវ |
| ២. មណ្ឌល បឋម. តាកែវក្រុង | ២០បន្ទប់ | ស្រុកដូនកែវ |
| ៣. មណ្ឌល វិ. សម្ដេចឪ | ២១បន្ទប់ | ស្រុកសំរោង |

| | | |
|---|---|---|
| ៤ មណ្ឌល វិ.១ឧសភា | ១៩បន្ទប់ | ស្រុកត្រាំកក់ |

### V. ខេត្តបាត់ដំបង មាន០៤មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ.ព្រះមុនីវង្ស | ១៨បន្ទប់ | ស្រុកបាត់ដំបង |
| ២. មណ្ឌល វិ.នេតយ៉ង់ | ៣០បន្ទប់ | ស្រុកបាត់ដំបង |
| ៣. មណ្ឌល បឋម.សម្ដេចជា ស៊ីម | ២០បន្ទប់ | ស្រុកបាត់ដំបង |
| ៤. មណ្ឌល បជ្ឈមណ្ឌលគរុ.ភូមិភាគ | ១១បន្ទប់ ក្នុងនោះបំ.វិ.០២បន្ទប់ | ស្រុកបាត់ដំបង |

### VI. ខេត្តព្រៃវែង មាន០៣មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ.ព្រះអង្គឌួង | ២៨បន្ទប់ | ស្រុកកំពង់លាវ |
| ២. មណ្ឌល សាលាគរុកោសល្យ | ១៨បន្ទប់ | ស្រុកកំពង់លាវ |
| ៣. មណ្ឌល វិ.ហ.សតាគោក | ២៧បន្ទប់ | ស្រុកព្រះស្ដេច |

### VII. ខេត្តបន្ទាយមានជ័យ មាន០២មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ.សម្ដេចឪ | ៣១បន្ទប់ | ស្រុកសិរីសោភ័ណ |
| ២. មណ្ឌល វិ.អង្គពររ៉ូវ | ១៨បន្ទប់ | ស្រុកមង្គលបូរី |

### VIII. ខេត្តកំពត មាន០២មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ.ព្រះរាជសម្ភារ | ៣៦បន្ទប់ | ស្រុកកំពង់បាយ |
| ២. មណ្ឌល បឋម.ហ.ស១មករា | ១១បន្ទប់ | ស្រុកកំពង់បាយ |

### IX. ខេត្តកំពង់ស្ពឺ មាន០៣មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ.ហ.សចំបក់ | ២០បន្ទប់ | ស្រុកសំរោងទង |
| ២. មណ្ឌល វិ.កំពង់ស្ពឺ | ១១បន្ទប់ | ស្រុកច្បារមន |
| ៣. មណ្ឌល អនុវិ.ទីរួមខេត្ត | ១៤បន្ទប់ | ស្រុកច្បារមន |

### X. ខេត្តកំពង់ធំ មាន០៣មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល វិ.កំពង់ធំ | ១៤បន្ទប់ | ស្រុកស្ទឹងសែន |
| ២. មណ្ឌល វិ.ហ.សបល្លង្ក | ១៥បន្ទប់ | ស្រុកស្ទឹងសែន |
| ៣. មណ្ឌល បឋម.កំពង់ធំក្រុង | ១៤បន្ទប់ | ស្រុកស្ទឹងសែន |

### XI. ខេត្តសៀមរាប មាន០២មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល បឋម. វត្តបូព៌ | ២៥បន្ទប់ | ស្រុកសៀមរាប |
| ២. មណ្ឌល វិ.១០ មករា ១៩៧៩ | ១៥បន្ទប់ | ស្រុកសៀមរាប |

### XII. ខេត្តស្វាយរៀង មាន០២មណ្ឌល :

| | | |
|---|---|---|
| ១. មណ្ឌល បឋម.ព្រះសីហនុ | ២៨បន្ទប់ | ស្រុកស្វាយរៀង |

| | | | |
|---|---|---|---|
| ២. | មណ្ឌល វិ. ហ៊ុន សែន (ប្រសូត្រ) | ០៩បន្ទប់ | ស្រុកស្វាយទាប |

XIII. ខេត្តពោធិសាត់ មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. ពោធិសាត់ | ៣៦បន្ទប់ | ស្រុកសំពៅមាស |

XIV. ខេត្តកំពង់ឆ្នាំង មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. ព្រះបាទសុរាម្រឹត | ២៤បន្ទប់ | ស្រុកកំពង់ឆ្នាំង |

XV. ក្រុងព្រះសីហនុ មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. ក្រុងព្រះសីហនុ | ១៨បន្ទប់ | ខ័ណ្ឌមិត្តភាព |

XVI. ខេត្តក្រចេះ មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. ព្រះមហា. កុសុមៈ | ១៦បន្ទប់ | ស្រុកចិត្របុរី |

XVII. ខេត្តស្ទឹងត្រែង មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល បឋម. អនុវត្ត | ០៥បន្ទប់ | ស្រុកស្ទឹងត្រែង |

XVIII. ខេត្តកោះកុង មាន០២មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. កោះកុង | ០២បន្ទប់ | ស្រុកស្មាច់មានជ័យ |
| ២. | មណ្ឌល វិ. ស្រែអំបិល | ០១បន្ទប់ | ស្រុកស្រែអំបិល |

XIX. ព្រះវិហារ មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. ត្បែងមានជ័យ | ០៣បន្ទប់ | ស្រុកត្បែងមានជ័យ |

XX. ខេត្តរតនគិរី មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. សម្ដេចឪសម្ដេចម៉ែ | ០២បន្ទប់ | ស្រុកបានលុង |

XXI. ក្រុងកែប មាន០១មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល អនុវិ. សង្គមរាស្ត្រនិយម | ០២បន្ទប់ | ស្រុកកែប |

XXII. ខេត្តមណ្ឌលគិរី មាន ០១ មណ្ឌល :

| | | | |
|---|---|---|---|
| ១. | មណ្ឌល វិ. សង្គមរាស្ត្រនិយម | ០២បន្ទប់ | ស្រុកសែនមនោរម្យ |

*ប្រការ២* : ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង និងនាយកគ្រឹះស្ថានសិក្សារបស់ខ្លួន ដែលត្រូវយកធ្វើជាមណ្ឌលប្រលងមានភារកិច្ចរៀបចំមណ្ឌលប្រលង និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តទៅនៃការប្រលងអោយហើយស្រេចមុនបើកសម័យប្រលង ។

*ប្រការ៣* :អគ្គនាយកអប់រំ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ច រៀងៗខ្លួន ដើម្បីអោយបានសំរេចតាមប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០០១

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

តូច សៀង

<u>កន្លែងទទួល</u> :

- ទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីសូមជ្រាបជាពត៌មាន"
- សាលាខេត្ត-ក្រុង "ដើម្បីជ្រាបជាពត៌មាន និងជួយសហការ"
- មន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- សាលារៀនក្រោមឱវាទផ្ទាល់របស់ក្រសួង អប់រំយុវជន និងកីឡា
- ពាណប្បវត្តិ
- ឯកសារ-នា. មចទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និង កីឡា
លេខ : 514 អយក.ប្រក

# ប្រកាស

ស្តីពីការបើកសាលាបឋមសិក្សា ត្រពាំងអង្គ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតលេខ : ១៤១៦ អយកត.បម ចុះថ្ងៃទី ១៣ មិនា ២០០១ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត តាកែវ
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១:** - បើកសាលាបឋមសិក្សា ត្រពាំងអង្គ ដែលមានទីតាំងស្ថិតនៅភូមិ ត្រពាំងអង្គ ឃុំ កំពែង ស្រុក ព្រៃកប្បាស ខេត្ត តាកែវ ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សាចំណោម ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ នេះតទៅ ។

**ប្រការ២:** - សាលាបឋមសិក្សា ត្រពាំងអង្គ ត្រូវមានប្រធានក្រុមម្នាក់ជាជំនួយការ លោក នាយកសាលាបឋមសិក្សាចំណោម ។

**ប្រការ៣:** - បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:** - នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត តាកែវ ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ព្រៃកប្បាស នាយកសាលាបឋមសិក្សា ចំណោម និង លោក ប្រធានក្រុមសាលា បឋមសិក្សាត្រពាំងអង្គមានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាបជាពត៌មាន"
- សាលាខេត្តតាកែវ "ជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ - ឯកសារ នា -ប.ម

ភ្នំពេញ ,ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០១
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

លេខ: 515 អយក.ប្រក

# ប្រកាស

ស្តីពីការបើកសាលាបឋមសិក្សា តន់ ហាន់

ជាសាលាបឋមសិក្សា ពេញលក្ខណៈ

~~~~~~~~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតលេខ :១០៥ អយក.សកត របស់ការិយាល័យអប់រំ យុវជន និង កីឡាស្រុកកំពង់ត្រាច ដោយមានចំណារឯកភាព របស់មន្ទីរអប់រំយុវជន និង កីឡា ខេត្តកំពត ចុះថ្ងៃទី ២១ / ៣ / ២០០១
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** : - បើកសាលាបឋមសិក្សា តន់ ហាន់ ដែលមានទីតាំងស្ថិតនៅ ភូមិព្រៃកក្រើស ឃុំព្រៃកក្រើស ស្រុកកំពង់ត្រាច ខេត្តកំពត ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ នេះតទៅ ។

**ប្រការ២** : - សាលាបឋមសិក្សា តន់ ហាន់ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : - នាយក នាយករង មានសិទ្ធិទទួលប្រាក់ប៉ំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : - បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** : - នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពត ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក កំពង់ត្រាច នាយកសាលាបឋមសិក្សា តន់ហាន់មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
-ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជូនជ្រាបជាពត៌មាន "
- សាលាខេត្តកំពត
" ដើម្បីជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៥

ភ្នំពេញ ,ថ្ងៃទី 06 ខែ កក្កដា ឆ្នាំ ២០០១

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី
~~~~~~~~~~~~~~~~~

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ : 516 អយក.ប្រក

# ប្រកាស

ស្តីពីការបើកសាលាបឋមសិក្សាឯកជន ឃូ.អេស.អេ

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ៦១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានពិនិត្យលិខិតលោក តាង ជិវ៉ាត់ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០១ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កំពង់ចាម លេខ ៧៩ អយក.កច ចុះថ្ងៃទី ៣១ មករា ២០០១ ។
-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

ប្រការ១ : - អនុញ្ញាតអោយលោក តាង ជិវ៉ាត់ បើកសាលាមត្តេយ្យ-បឋមសិក្សាចំនេះទូទៅឯកជន ឃូ.អេស.អេ ដែលមានទីតាំងស្ថិត នៅផ្លូវ នាងគង្ហីង ភូមិ ទាវ កង្ហិង ឃុំ សំបូរមាស ស្រុក កំពង់ចាម ខេត្ត កំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ នេះតទៅ ។

ប្រការ២ : -ចំពោះមុខវិជ្ជាលានេះ និងបណ្តុះបណ្តាលចំនេះទូទៅតាមបែបអន្តរជាតិ ដែលចែកចេញជាថ្នាក់សំរាប់សិក្សារយៈពេល ១ ឆ្នាំ ។

| | | |
|---|---|---|
| - ថ្នាក់កំរិតទាប Lower Step | - ថ្នាក់ទី ១ Grade one | - ថ្នាក់ទី ៤ Grade Four |
| ថ្នាក់កំរិតមធ្យម Medium Step | - ថ្នាក់ទី ២ Grade Two | - ថ្នាក់ទី ៥ Grade Five |
| - ថ្នាក់កំរិតខ្ពស់ High Step | - ថ្នាក់ទី ៣ Grade Three | - ថ្នាក់ទី ៦ Grade Six |

ទៅអនាគតសាលានេះ និង អាចពង្រីកបើកបន្ថែមទៅតាមលទ្ធភាពរបស់ខ្លួន ។

ប្រការ៣:- ការទទួលសិស្សអោយចូលរៀន : សិស្សទាំងពីរភេទត្រូវមានអាយុ ចាប់ពី ៣ ឆ្នាំឡើងទៅពេញ :

ប្រការ៤ :- លោក តាង ជិវ៉ាត់ មានភារកិច្ច :

- ជ្រើសរើសសិស្សអោយចូលរៀន គ្រូបង្រៀន ដំណើរការបង្រៀន ឯកសារសិក្សា ការប្រលង និងការប្រគល់វិញ្ញាបនប័ត្របញ្ចប់ការសិក្សា ។
- គោរពនិងអនុវត្តតាមសារាចរ និង សេចក្តីណែនាំរបស់រដ្ឋ ។
- ធានាអោយបាននូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- រាយការណ៍រាល់សកម្មភាពបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និង កីឡា

ប្រការ៥ :- ក្រសួងអប់រំ យុវជន និង កីឡា មានសិទ្ធិធ្វើអធិការកិច្ចត្រួតពិនិត្យហើយមានសិទ្ធិបិទ ប្រសិនបើសាលានេះ អនុវត្តខុសពីច្បាប់រដ្ឋ ។

ប្រការ៦ :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំយុវជន និង កីឡា ខេត្ត កំពង់ចាម ការិយាល័យអប់រំយុវជន និង កីឡា ស្រុក កំពង់ចាម នាយកសាលាមត្តេយ្យ-បឋមសិក្សា ឃូ.អេស.អេ និង លោក តាង ជិវ៉ាត់ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ .ថ្ងៃទី 06 ខែ កក្កដា ឆ្នាំ ២០០១

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្ត កំពង់ចាម

ដើម្បីជូនជ្រាបជាពត៌មាន

- ដូចប្រការ ៦
- កាលប្បវត្តិ- ឯកសារ -នា.បម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៛ ❖ ៛៚

**ក្រសួងអប់រំយុវជន និង កីឡា**

**លេខ :** 517 **អយក.ប្រក**

# ប្រកាស

ស្តីពីការបើកសាលាបឋមសិក្សាឯកជន ខ្មែរ-ចិន **ទៃ អ៊ីង**

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់លោក **គាង ឈី** ចុះថ្ងៃទី ០៦ -ធ្នូ ១៩៩៩ ដោយមានចំណារឯកភាពរបស់មន្ទីរ អប់រំ យុវជន និង កីឡា កោះកុង ចុះថ្ងៃទី ១៣ ធ្នូ ១៩៩៩ ។
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

